ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៩៦
ចុះថ្ងៃទី១៦-សីហា-២០០៤
សាលដីកាលេខៈ១០៣
ចុះថ្ងៃទី២៨-១២-២០០៥

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅៈ

១-ឯកឧត្តម... ប្រធាន
២-លោក... ចៅក្រម
៣-លោក... ចៅក្រម
៤-លោក... ចៅក្រម
៥-លោក.... ចៅក្រម
៦-លោក ... ចៅក្រម
៧-លោក... ចៅក្រម
៨-លោក... ចៅក្រម
៩-លោក... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ

ឯកឧត្តម...អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល។

**ពីបទ** ជួញគ្រឿងញៀន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១-ជនជាប់ចោទឈ្មោះ ឈចថ (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុសអាយុ៣០ឆ្នាំ ជាតិខ្មែរ របររកស៊ីឃោធា ទីលំនៅមុនថ្ងៃចាប់ខ្លួន នៅក្រុមទី៨ មណ្ឌល៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូនពីរនាក់។ ក្នុងឃុំ។

២-ជនជាប់ចោទឈ្មោះ **ឈធ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ីរត់ម៉ូតូឌុប ទីលំនៅមុនពេលចាប់ខ្លួន មណ្ឌល០១ សង្កាត់០៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០២នាក់។

-មានមេធាវីលោក...

៣-ជនជាប់ចោទឈ្មោះ **សវសន** ភេទប្រុសអាយុ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ីនរគបាលប៉ុស្តិ៍នាងកុក ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិនាងកុក ឃុំបាក់ខ្លង ស្រុកកោះកុង ខេត្តកោះកុង ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ... ប្រពន្ធឈ្មោះ...មានកូន០២នាក់ ។ ក្នុងឃុំ។

៤-ជនជាប់ចោទឈ្មោះ **ឈចដរ** ភេទប្រុសអាយុ២៨ ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មកររនេសាទ ទីលំនៅមុនថ្ងៃចាប់ខ្លួននៅក្រុម២៧ មណ្ឌល៣ ខណ្ឌ

មិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ...ម្ដាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន ០១នាក់។

៥-ជនជាប់ចោទឈ្មោះ **អអ** ភេទស្រីអាយុ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ត្រី ទីលំនៅមុនពេលចាប់ខ្លួននៅភូមិនាងកុក ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។ ឪពុកឈ្មោះ...ម្ដាយឈ្មោះ...ប្ដីឈ្មោះ...មានកូនបីនាក់។

-តាមកំណត់ហេតុចាប់ដាក់ស្ដែងថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន បានចាប់ជនល្មើសចំនួន២នាក់ គឺឈ្មោះ **ឈច** និង **ឈចថ** ដោយនៅពេលចាប់ជនល្មើសនេះ បានដកហូតវត្ថុតាងម្សៅហេរ៉ូអ៊ីន ១,៤គីឡូ និងតាមកំណត់ហេតុស្ដីពីការធ្វើតេស្ដលើម្សៅដែលបានរឹបអូសពីជនល្មើសឈ្មោះ **ឈច** ជាមួយប្រតិករ មានប្រតិកម្មវិជ្ជមានជាហេរ៉ូអ៊ីន និងបានយកហេរ៉ូអ៊ីន ដាក់បញ្ចូលក្នុងស្បោងផ្លាស្ទិក ដែលមានលេខសំគាល់៥K២៤៧៩៥២ និងអ៊ុតផ្សិត។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញសម្រេច ចោទប្រកាន់ឈ្មោះ **សវសន, ឈចថ, ឈច, ឈចដរ** និង **អអ** ពីបទជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ខែតុលាឆ្នាំ១៩៩៧ បទល្មើសព្រហ្មទណ្ឌ មានចែងនិងផ្ដន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ស្ដីពីការត្រួតពិនិត្យ គ្រឿងញៀន និងបង្គង់បណ្ដឹងអាជ្ញាលើគូកន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេច។

១-បង្គង់បណ្ដឹងអាជ្ញាលើឈ្មោះ **ទអ** និងឈ្មោះ **រ** ពីបទជួញគ្រឿងញៀន នៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ ព្រោះគ្មានសារតាជាតិ។

២-ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ **សវសន** ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ឈ្មោះ **ឈចថ** ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ.ឈ្មោះ **ឈធ** ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ,ឈ្មោះ **ឈចដរ** ភេទប្រុស ជាតិខ្មែរ និង ឈ្មោះ**អអ** ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ ក្នុងម្នាក់ៗចំនួន១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី១៣ ខែតុលា ឆ្នាំ១៩៩៧ ពីបទជួញគ្រឿងញៀននៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ តាមមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-រឹបអូសម៉ៅគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនទម្ងន់១.៤០០ក្រាម ដែលឃុំបេជិត ដាក់ថង់លេខ៥K២៤៧៩៥២ ដើម្បីបំផ្លាញចោល។

៤-ប្រគល់នាឡិកាដៃម៉ាកអូប៉េ ពណ៌លឿងលេខ៨៩៣២ មួយគ្រឿង ប័ណ្ណសំគាល់សមាជិកលេខសន០១០០៧ យឆ ប័ណ្ណអាវុធវែងមួយសន្លឹកលេខចូលបញ្ជី២១៦-៩៧ ប័ណ្ណសំគាល់ខ្លួន មួយសន្លឹកលេខអឹម០៤-៩៧ក-២ឱ្យទៅឈ្មោះ **ឈចថ** វិញ។

ប្រគល់ត្បូងពណ៌ក្រហមចំនួន៣៦គ្រាប់ ខ្សែកមួយខ្សែប្រវែង៦តឹក ជាលោហៈពណ៌លឿង បណ្តោងរូបព្រះចំនួនពីរ ស្រោបដោយលោហៈពណ៌លឿង ខ្សែដៃមួយខ្សែមានដាំត្បូងពណ៌ក្រហម ចំនួន១៥គ្រាប់ឱ្យទៅឈ្មោះ**អអ**។

ប្រគល់លិខិតសំគាល់ខ្លួនលេខក០០២៦៥៩ អត្តសញ្ញាណប័ណ្ណលេខ០៣០៩៦៥កក៤ឱ្យឈ្មោះ **សវសន**។

៥-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ សម្រេចបើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៧(ក) ចុះថ្ងៃទី១០ខែមេសាឆ្នាំ១៩៩៨ របស់ឈ្មោះ **អអ ឈចដរ ឈចថ, សវសន, ឈធ** ប្តឹងមិនសុខចិត្តនឹង

សាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ២៧"ក" ចុះថ្ងៃទី១០ខែមេសាឆ្នាំ១៩៩៨ របស់ជនជាប់ចោទ **អអ,ឈចដរ, ឈធ, ឈចថ** និង **សរសន**ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញទុកជាបានការតទៅ លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេច ដែលត្រូវបដិសេធចោលជាអសារបង់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះ **អអ,ឈចដរ,ឈចថ,សរសន** និង **ឈធ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល គ្រាន់តែកែប្រែរយៈពេលនៃការផ្តន្ទាទោសលើឈ្មោះ **អអ,ឈធ និង ឈចថ** ក្នុងចំណុចទី២ នៃសេចក្តីសម្រេចពី១០ឆ្នាំ មក៧ឆ្នាំ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ **ឈធ, ឈចថ,ឈចដរ,សរសន** និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ **អអ** បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៦៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា: តុលាការក្រុងភ្នំពេញក៏ដូចសាលាឧទ្ធរណ៍ដែលសម្រេចបង្អង់បណ្តឹងអាជ្ញាលើឈ្មោះ **ទអ** និង **រ** ដោយហេតុថា គ្មានសាវតាជាតិច្បាស់លាស់ នោះជាការភាន់ច្រឡំ ពីព្រោះថា តាមចម្លើយជនជាប់ចោទឈ្មោះ **សរសទ និង ឈចជរ** នៅចំពោះមុខនគរបាលប្រឆាំងគ្រឿងញៀន ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧ ថា **រ** មានឈ្មោះពិត **ទរ** ធ្វើនគរបាលមានទីលំនៅៗត្រង់ផែអូរប័រនាងកុក, ឈ្មោះអូនមានមុខរបរជានគរបាលប៉ុស្តិ៍នាងកុក។

-ការដែលសាលាឧទ្ធរណ៍ សម្រេចកែប្រែ រយៈពេលនៃការផ្តន្ទាទោសឈ្មោះ **អអ, ឈធ និង ឈចថ** ពី១០ឆ្នាំមក៧ឆ្នាំ ដោយអាងហេតុថា នាពេលសវនាការនៅសាលាឧទ្ធរណ៍ ជនជាប់ចោទបានឆ្លើយទទួលស្គាល់កំហុសរបស់ខ្លួន ហើយមានស្មារតីភ្ញាក់រលឹកកែប្រែខ្លួនឱ្យក្លាយជាមនុស្សត្រឹមត្រូវវិញ នោះគឺជាការភាន់ច្រឡំ ពីព្រោះថាសំអាងហេតុនេះពុំមែនជាស្ថានសម្រាល ដែលសាលាឧទ្ធរណ៍លើកយកមកពិចារណាក្នុងពេលនេះឡើយ។

-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលបានសម្រេច

-ទទួលបណ្តឹងសាទុក្ខលេខ៦៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់។

២-ទទួលបណ្តឹងសាទុក្ខលេខ៦៥ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ របស់លោក...បណ្តឹងសាទុក្ខលេខ៦៧ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះ **ឈឋ** និងបណ្តឹងសាទុក្ខលេខ៧២ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះ **ឈចជវ** និងឈ្មោះ **ឈចថ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

៣-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចផ្តន្ទាទោសឈ្មោះ **សវសន** ដែលត្រូវតម្កល់ទុកជាបានការ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៩០ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០២។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១-ទទួលជំនុំជម្រះជាថ្មីឡើងវិញ តាមអំណាចសាលដីកាបស់តុលាការកំពូល។

២-តម្កល់សាលក្រមលេខ២១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការតទៅ លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេច ត្រូវបដិសេធចោលជាអសារបង់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៩(ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចៈ

១-ទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ២៣៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ របស់តុលាការកំពូល។

២-ផ្តន្ទាទោសលើឈ្មោះ

-**ឈចថ** ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ

-**ឈច** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ

-**ឈចដរ** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ

-**អអ** ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ ពីបទជួញដូរគ្រឿងញៀន ប្រព្រឹត្តកាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ នៅក្រុងភ្នំពេញ តាមមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ **ឈចថ,ឈច,ឈចដរ** ចំពោះមុខមេធាវីការពារជនជាប់ចោទកំបាំងមុខឈ្មោះ **អអ** សម្រេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះ **ឈចថ** និងឈ្មោះ **ឈច** ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៩(ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះ **ឈធ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់។

-បានឃើញសារណា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ**ឈចដរ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់។

-បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះត្រឹមត្រូវ ប៉ុន្តែសាលាឧទ្ធរណ៍មិនបានសម្រេចបង្គង់បណ្តឹងអាជ្ញាលើឈ្មោះ អូន និង ឈ្មោះ **ទរ** ដោយឡែកវត្ថុតាងសាលាឧទ្ធរណ៍ពុំបានសម្រេចរឹបអូសចំណាយចោលទេ។ សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យ និងសម្រេច។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ **ឈចថ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថាៈ សូមតុលាការកំពូល សម្រេចតាមសាលដីកាលើកទី១ របស់សាលាឧទ្ធរណ៍ ខ្ញុំព្រមទទួលទោស៧ឆ្នាំ ខ្ញុំភ្ញាក់រលឹកកែប្រែខ្លួន សូមតុលាការបន្ធូរបន្ថយទោសដល់ខ្ញុំបាទផង ណាមួយខ្ញុំបាទជាប់ពន្ធនាគារ៨ឆ្នាំ ហើយ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ **ឈធ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថាៈ ខ្ញុំឯកភាពតាមចម្លើយរបស់ឈ្មោះ **ឈចថ** សូមតុលាការបន្ធូរបន្ថយទោសខ្ញុំផង។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក...ជាមេធាវីការពារជនជាប់ចោទឈ្មោះ **ឈធ** និង **ឈចថ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថាៈ កូនក្តីខ្ញុំបាទចាញ់បោកគេ ល្ងិតល្ងង់មិនយល់ដឹងពីច្បាប់មានប្រពន្ធមានកូន មានឪពុក

ម្តាយចាស់ជរា ហើយបានទទួលសារភាព និងមានសំបុត្របញ្ជាក់ពីពន្ធនាគារ។ សូមតុលាការបន្ធូរបន្ថយទោសផង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការអម តុលាការកំពូល នៅពេលជំនុំជម្រះថាៈ គ្មានយោបល់បន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ **ឈចថ** និងឈ្មោះ **ឈធ** និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ របស់ជនជាប់ចោទ ឈ្មោះ **ឈចថ** និងឈ្មោះ **ឈធ** ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះដល់អង្គសេចក្តីបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថាៈ ជនជាប់ចោទនៅក្នុងរឿងនេះ ដែលក្នុងនោះក៏មាន ឈ្មោះ **ឈធ** និងឈ្មោះ **ឈចថ** ដែរ បានសារភាពពីអំពើរបស់ខ្លួននៅចំពោះ មុខការស៊ើបសួរ និងចំពោះមុខសវនាការកន្លងមក ដែលមានលក្ខណៈស៊ីសង្វាក់ គ្នាជាមួយនឹងវត្ថុតាង គឺមេទ្បាំហេរ៉ូអ៊ីនចំនួន១,៤០០ក្រាម ដែលត្រូវបានរឹបអូស ជាក់ស្តែងពីការកាន់កាប់របស់ក្រុមជនជាប់ចោទនៅថ្ងៃចាប់ខ្លួន។

-យល់ឃើញថាៈ ការដែលសាលាឧទ្ធរណ៍ សម្រេចផ្តន្ទាទោសដាក់ពន្ធ នាគាដល់ជនជាប់ចោទឈ្មោះ **ឈធ** និង ឈ្មោះ **ឈចថ** ម្នាក់ៗចំនួន១០ឆ្នាំនោះ

ជាការត្រឹមត្រូវតាមការកំណត់នៃមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនហើយៗ ការដែលជនជាប់ចោទឈ្មោះ **ឈចថ** លើកឡើងពីការកែប្រែខ្លួន និងបានផ្តល់សំអាងជាលិខិតបញ្ជាក់របស់ប្រធានពន្ធនាគារដែលមានន័យថា ឈ្មោះនេះបានកែប្រែខ្លួន និងមានការគោរពវិន័យពន្ធនាគានោះ គឺពុំមែនជាមូលហេតុ ឬ ជាស្ថានភាព ដែលអាចធ្វើការពិចារណាពីស្ថានបន្ធូរបន្ថយទោសបាននោះឡើយ។

-យល់ឃើញថាៈ ក្នុងការសម្រេចសេចក្តីជាថ្មីសាលាឧទ្ធរណ៍ពុំបានសម្រេចអំពីការបង្គង់បណ្តឹងអាជ្ញា លើឈ្មោះ **ទរ** និងឈ្មោះ **អ** ដូចការចង្អុលបង្ហាញរបស់តុលាការកំពូលទេ ដែលគប្បីតុលាការកំពូលពិចារណា និងសម្រេចបន្ថែម។

-យល់ឃើញថាៈ តាមចម្លើយរបស់ឈ្មោះ **ឈចជរ** និងឈ្មោះ **សវសន** នៅចំពោះមុខនគរបាលយុត្តិធម៌កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧ ថា ឈ្មោះ **វ** មានឈ្មោះពិត គឺ **ទរ** មានមុខរបរធ្វើនគរបាល និងមានទីលំនៅត្រង់ផែអូប៉័រនាងកុក រីឯឈ្មោះ **អ** គឺ **ទអ** មានមុខរបរជានគរបាលនៅប៉ុស្តិ៍នាងកុក ហើយម្យ៉ាងទៀតបទល្មើសដែលត្រូវចោទប្រកាន់ នៅមិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសនៅឡើយទេ ដែលគប្បីតុលាការក្រុងភ្នំពេញ លើកយកករណីជនពីររូបនេះមកចាត់ការបន្ត។

-យល់ឃើញថាៈ នៅក្នុងរឿននេះមានវត្ថុតាង ដែលត្រូវបានរឹបអូសមានដូចជា ម្សៅហេរ៉ូអ៊ីន ចំនួន១.៤០០ក្រាម និង វត្ថុប្រើប្រាស់របស់ជនជាប់ចោទ តែសាលាឧទ្ធរណ៍ មិនទាន់បានសម្រេចពីវាសនានៃវត្ថុតាងទាំងនោះឡើយ។

-យល់ឃើញថាៈ ការដែលជនជាប់ចោទទាំងពីរនាក់ ក៏ដូចមេធាវីរបស់ឈ្មោះទាំងពីរនាក់នេះដែរ ដែលសុំឱ្យតុលាការកំពូលបន្ធូរបន្ថយទោសនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះទណ្ឌកម្ម ដែលតុលាការថ្នាក់ក្រោមកំណត់នេះ មានកម្រិតអប្បបរិមានៃទោសហើយ។

-យល់ឃើញថាៈ សាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហាឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់ហើយ តែមានចំណុចខ្វះចន្លោះ ដែលត្រូវសម្រេចបន្ថែម។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ **ឈចថ** និង **ឈធ**

១-ទទួលបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ របស់ជនជាប់ចោទឈ្មោះ **ឈចថ** និងឈ្មោះ **ឈធ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ដោយសម្រេចបន្ថែម។

៣-ក/ -បង្គាប់ឱ្យតុលាការក្រុងភ្នំពេញចាត់ការលើឈ្មោះ **ទវ** និងឈ្មោះ **ទអ** ឡើងវិញ តាមដីកាលេខ១៤៩៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៧ និងលេខ១៦១៤ ចុះថ្ងៃទី២៩ខែតុលាឆ្នាំ១៩៩៧ របស់អយ្យការក្រុងភ្នំពេញ។

ខ/-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការបន្តតាមសមត្ថកិច្ច។

៤-វត្ថុតាងមានៈ

ក/-ម៉េរ៉ូហេរ៉ូអ៊ីន១,៤០០ក្រាម ដាក់ក្នុងថង់លេខ៥K២៤៧៩៥២ ត្រូវរឹបអូស និងបំផ្លាញចោល។

ខ/-នាឡិកាដៃម៉ាកOP ពណ៌លឿងលេខ8932E ចំនួន០១គ្រឿង ប័ណ្ណសំគាល់សមាជិកលេខសន០១០០៧ យឆ ប័ណ្ណអាវុធវែងលេខចុះបញ្ជី២៦៦-៩៧,ប័ណ្ណសំគាល់ខ្លួនលេខM04/97ក២ ត្រូវប្រគល់ឱ្យទៅឈ្មោះ**ឈចថ**វិញ។

-ត្បូងពណ៌ក្រហមចំនួន៣៦គ្រាប់, ខ្សែកមួយខ្សែប្រវែង០,៦ម ជាលោហៈធាតុពណ៌លឿង ខ្សែដៃមួយមានដាំត្បូង ពណ៌ក្រហមចំនួន១៥គ្រាប់ ត្រូវប្រគល់ឱ្យទៅឈ្មោះ **អអ** វិញ។

-លិខិតសំគាល់ខ្លួនលេខក០០២៦៥៩, អត្តសញ្ញាណប័ណ្ណលេខ០៣០៩៦៥ក-ក៤ ត្រូវប្រគល់ឱ្យឈ្មោះ **សវសន** វិញ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥។